# ច្បាប់
# ស្តីពី
# ព្រៃឈើ

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផលការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ ។

មាត្រា ២.-

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះ កើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី ។

រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋាន ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

មាត្រា ៣.-

ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិ ទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃ ទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការ អនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោម ការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

មាត្រា ៤ .-

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ។

សកម្មភាពចម្បងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គមនិងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជានិង ស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់

សង្គម។ ការសម្រេចចុងក្រោយណាមួយក្រោម មាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ។

មាត្រា ៥ .-

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះត្រូវបានកំណត់ ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## រដ្ឋបាលព្រៃឈើ

មាត្រា ៦ .-

រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាល ដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ។

រដ្ឋបាលព្រៃឈើមានរចនាសម្ព័ន្ធគ្រប់គ្រង ចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយ ដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខ័ណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ ត្រូវកំណត់ដោយប្រកាសរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

រដ្ឋបាលព្រៃឈើត្រូវបំពេញភារកិច្ចរបស់ខ្លួន ស្របតាមគោលការណ៍តម្លាភាពដោយធានានូវសិទ្ធិរបស់សាធារណជន ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង ការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ។

មាត្រា ៧ .-

រដ្ឋបាលព្រៃឈើត្រូវបំពេញនូវភារកិច្ចដូចតទៅ ៖

១- ធានាដល់ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ប្រកបដោយនិរន្តរភាពដោយដាក់បទបញ្ញាលើរាល់សកម្មភាពព្រៃឈើ ។

២- សិក្សាប្រមូលទិន្នន័យលើព្រៃឈើរដ្ឋទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់នូវកំរិតផ្តល់ផលប្រកបដោយនិរន្តរភាព ។

៣- វាយតម្លៃព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ដែនព្រៃឈើ ដើម្បី បង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន។

៤- រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិនៅថ្នាក់នីមួយៗនៃរដ្ឋបាលព្រៃឈើ។

៥- បង្កើនការដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរឹល និងដីព្រៃទំនេរ។

៦- បង្កើនការអភិវឌ្ឍន៍កិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើ ដោយផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍តាមការសមស្រប។

៧- អភិវឌ្ឍ និងអនុវត្តកម្មវិធីស្រាវជ្រាវ ការពារនិងថែរក្សាធនធានព្រៃ ឈើនិងសត្វព្រៃ។

៨- ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាលការបំផ្លិចបំផ្លាញព្រៃឈើ ភ្លើងឆេះព្រៃ និងការកាប់រានព្រៃឈើ ដោយធានាការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព។

៩- បង្កើនការអប់រំដល់ប្រជាពលរដ្ឋតាមរយៈកម្មវិធីដែលបង្ហាញពីសារៈសំខាន់ក្នុងការគ្រប់គ្រង ការពារថែរក្សាធនធានព្រៃឈើ ក៏ដូចជាចាត់វិធានការស្តារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងថែរក្សាព្រៃឈើជាតិ។

១០- បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅពង្រឹងសមត្ថភាពការពារ និងអភិវឌ្ឍធនធានព្រៃឈើ។

១១- ធានាការវាយតម្លៃទាន់ពេលវេលា និងពេញលេញនូវរាល់សកម្ម ភាពទាក់ទងនឹងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានមុនការឯកភាពលើសកម្មភាពទាំងនេះ។

មន្ត្រីរដ្ឋបាលព្រៃឈើមានសិទ្ធិនិងភារកិច្ចដូចខាងក្រោម ៖

១-ត្រួតពិនិត្យការធ្វើអាជីវកម្មប្រមូលផល អនុផលព្រៃឈើក្នុងដែន ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងចំការដាំឈើរបស់រដ្ឋ។

២- ត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ និងផលប្រមាញ់ តាមមធ្យោបាយដឹកជញ្ជូននានា។

៣- ត្រួតពិនិត្យកន្លែងសន្និធិផល អនុផលព្រៃឈើ ទីតាំងលក់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ។

៤- ត្រួតពិនិត្យមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្ម កែច្នៃផល អនុផលព្រៃឈើ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផលអនុផលព្រៃឈើ ជាវត្ថុធាតុដើម ឬប្រភពថាមពលអំពីឈើ។

៥- ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀតដែលតម្រូវឱ្យត្រួតពិនិត្យតាមច្បាប់នេះ។

## ជំពូកទី ៣
## និរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ

មាត្រា ៨ .-

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវអនុវត្តស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់នេះ។

ដើម្បីជំនួយឱ្យការសិក្សាស្រាវជ្រាវគោលនយោបាយវិស័យព្រៃឈើជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋា-ភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យ ព្រៃឈើជាតិដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមានសមាជិកពីក្រសួងពាក់ព័ន្ធនឹងវិស័យព្រៃឈើ។ ផ្អែកតាមអនុ-សាសន៍របស់គណៈកម្មាធិការជាតិ រៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រាជរដ្ឋាភិបាលត្រូវកំណត់នូវគោលនយោបាយ វិស័យព្រៃឈើជាតិ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

គោលនយោបាយវិស័យព្រៃឈើជាតិ អាចសើរើដោយរាជរដ្ឋាភិបាលដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ក្នុងលក្ខខណ្ឌផ្លាស់ប្តូរនៃស្ថានភាពវិស័យព្រៃឈើតាមគោលការណ៍ដែលនាំមកនូវដំណោះស្រាយ ដើម្បីរក្សានិរន្តរភាពនៃការគ្រប់គ្រងព្រៃឈើ។

មាត្រា ៩ .-

រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ ដោយមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធនិង សហគមន៍មូលដ្ឋានដែលអនុលោមតាមមាត្រា ៤ នៃច្បាប់នេះ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវសម្រេចដោយរាជរដ្ឋាភិបាលសំរាប់រយៈពេលវែង ដើម្បីកំណត់អាទិភាព និងសកម្មភាពគ្រប់គ្រងព្រៃឈើ។ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់ ៥ឆ្នាំ ម្តង ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌ និងកាលៈទេសៈផ្លាស់ប្តូរ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ ត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិដែលបានសើរើ ។

ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ត្រូវលើកឡើងនូវសមាសភាគដូចតទៅ ៖

១- ពិនិត្យកត្តារូបសាស្ត្រ បរិស្ថាន និងសង្គមទាក់ទងនឹងធនធានព្រៃឈើនៅគ្រប់ថ្នាក់នៃរដ្ឋបាលព្រៃឈើ ។

២- ប៉ាន់ស្មានបរិមាណផល អនុផលព្រៃឈើគ្រប់លំដាប់ថ្នាក់។

៣- កំណត់ផ្ទៃដីតំបន់ព្រៃឈើ តំបន់ត្រូវដាំឈើឡើងវិញ និងព្រៃសហគមន៍។

៤- ពិនិត្យកម្មវិធី និងប្រតិទិនសកម្មភាពលំអិតលើការងាររៀបចំព្រៃឈើ និងរុក្ខវប្បកម្ម។

៥- អភិវឌ្ឍកម្មវិធីនៃការធ្វើអន្តរាគមន៍ ដល់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើរដ្ឋនិងឯកជន។

៦- អភិវឌ្ឍកម្មវិធីសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ទីផ្សារផល អនុផលព្រៃឈើ។

៧- អភិវឌ្ឍកម្មវិធីស្រាវជ្រាវស្តីពីការអភិវឌ្ឍន៍បច្ចេកវិជ្ជា និងវិទ្យាសាស្ត្រព្រៃឈើ។

៨- បង្កើននិងពង្រីកចំណេះដឹងពីព្រៃឈើដោយអញ្ជើញការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងប្រើប្រាស់និងការពារព្រៃឈើ។

៩- អភិវឌ្ឍធនធានមនុស្ស និងមធ្យោបាយសម្ភារៈចាំបាច់ ដើម្បីសម្រេចលើសកម្មភាពដែលបានគ្រោងនៅក្នុងកម្មវិធី។

១០- ពង្រឹងស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើនៅគ្រប់ថ្នាក់ កែលំអ និងពង្រឹងការអនុវត្តន៍ច្បាប់។

១១- ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេសក្នុងតំបន់ និងក្រៅតំបន់ក្នុងកិច្ចការពារនិងអភិវឌ្ឍន៍ធនធានព្រៃឈើ។

១២- ឧបត្ថម្ភគាំទ្ររាល់កម្មវិធីទាំងឡាយណា ដែលជំរុញឱ្យមានការអនុវត្តន៍គោលនយោបាយវិស័យព្រៃឈើជាតិ។

ផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យព្រៃឈើជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តន៍នូវគោលបំណងនៃផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិជូនរាជរដ្ឋាភិបាល។ របាយការណ៍នេះ ត្រូវផ្តល់ជូនជាសាធារណៈតាមការស្នើសុំ។

# ជំពូកទី ៤
# សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

មាត្រា ១០ .-

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន ៖

១- ព្រៃបម្រុងទុកអចិន្ត្រៃយ៍។

២- ព្រៃឯកជន។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ ៖

១- ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះ មុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃផ្តល់ផលមានជាអាទិ៍ ៖

- ព្រៃសម្បទាន
- ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- ព្រៃឈើត្រូវស្តារឡើងវិញ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចំការព្រៃឈើ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ
- ផ្ទៃដីព្រៃរេចរឹល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង។

២- ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។ ព្រៃការពារមានជាអាទិ៍ ៖

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជំរាល
- ព្រៃលំហែកំសាន្ត
- សួនរុក្ខជាតិ
- ព្រៃជំនឿសាសនា ។

ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន។

៣- ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃ បន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍសម្រាប់គោលបំណងផ្សេងទៀត ដោយរាជរដ្ឋាភិបាល។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់។